**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
## រវាង
## រោងចក្រ ជេ-កូវី បេស (ខេមបូឌា) ឯ.ក
## ជាមួយប្រតិភូបុគ្គលិក តំណាងកម្មករនិយោជិតទាំងអស់

នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៥ វេលាម៉ោង ៨:០០ព្រឹក នៅសហគ្រាស **ជេ-កូវី បេស (ខេមបូឌា) ឯ.ក** មានកិច្ចប្រជុំមួយរវាងរដ្ឋបាល និងប្រតិភូបុគ្គលិក ជំនួសឲ្យកម្មករនិយោជិតសរុបចំនួន ១៥នាក់។ ក្នុងអង្គប្រជុំនេះប្រធានរដ្ឋបាលបានជូនដំណឹងដល់ប្រតិភូបុគ្គលិក ស្តីពីស្ថានភាពបច្ចុប្បន្ននៃរោងចក្រដែលមិនមានការបញ្ជាទិញនាំឱ្យមានផលប៉ះពាល់ដល់រោងចក្រ។ ហេតុដូចនេះរោងចក្រសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន **១៣នាក់ (ស្រី ៤នាក់)** ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៥នាក់ (ស្រី៤នាក់) រយៈពេល**៥២ថ្ងៃ** ដោយគិតចាប់ពី**ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៥** ដល់**ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥**។ ក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកការផ្តល់ជូនរបស់រោងចក្រនូវប្រាក់ឧបត្ថម្ភចំនួន ៦០ដុល្លា (60$) ក្នុងនោះ៖

- **ចំនួន៣០ដុល្លា ពីថ្ងៃទី១០ ដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥**
- **ចំនួន៣០ដុល្លា ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥**

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងារនេះនឹងបើកជូនកម្មករនិយោជិតនៅរៀងរាល់**ថ្ងៃទី១០**នៃខែបន្ទាប់។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ៨:៥០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែលប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

រាជធានីភ្នំពេញ, ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៥

ហត្ថលេខា និងត្រាក្រុមហ៊ុន

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ជេ-កូវី បេស (ខេមបូឌា) ឯ.ក
J-KOVI BEST (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

KIM HWI SUN

ស្នាមមេដៃប្រតិភូបុគ្គលិក